ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ

សំណុំរឿងព្រហ្មទណ្ឌលេខ : ៥៨២
ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០២១
សាលក្រមព្រហ្មទណ្ឌលេខ : ២២៩/១២ "ឃ"
ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តព្រះសីហនុ

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការ សាលាដំបូងខេត្តព្រះសីហនុ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ០៨ និង ៣០នាទី ព្រឹក និងប្រកាសសាលក្រម នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ ដែលមានសមាសភាព ដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] ជាប្រធានក្រុមប្រឹក្សា
-ឯកឧត្តម [redacted] ជាចៅក្រមក្រុមប្រឹក្សា
-លោកស្រី [redacted] ជាចៅក្រមក្រុមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ

**ដើម្បីជំនុំជម្រះ**

សំណុំរឿងព្រហ្មទណ្ឌលេខ: **៥៨២ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១** ដែលមាន៖

**-ជនជាប់ចោទ ៖**

១-ឈ្មោះ [redacted] **លីហួរ ហៅ ហ័រ** ភេទប្រុស អាយុ១៦ឆ្នាំ (កើតឆ្នាំ២០០៥) ជនជាតិខ្មែរ មានទីកន្លែងកំណើត [redacted] មានទីលំនៅបណ្ដោះអាសន្នមុនពេលឃាត់ខ្លួន ភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មុខរបរ សិស្ស កម្រិតវប្បធម៌ ថ្នាក់ទី៩ នៅលីវ ឪពុកឈ្មោះ [redacted] សុភី (រស់) ម្ដាយឈ្មោះ (មិនស្គាល់ឈ្មោះ) ជាអនីតិជន ប្រវត្តិនៃការផ្ដន្ទាទោសពីមុន (គ្មាន) ។

-ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ៦២០ តពជ/២១ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ ។

-ជាប់ចោទពីបទ៖ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** និងបទ៖ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាម មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ឈ្មោះ [redacted] **កែវខាយាង** ហៅ ជួយ ភេទប្រុស អាយុ២០ឆ្នាំ (កើតថ្ងៃទី២៩.០៤.២០០១) ជនជាតិខ្មែរ មានទីកន្លែងកំណើត [redacted] ខេត្តព្រះសីហនុ មានទីលំនៅបណ្ដោះអាសន្នមុនពេលឃាត់ខ្លួន [redacted] ខេត្តព្រះសីហនុ មុខរបរ មិនពិតប្រាកដ



Scanned with CamScanner

កម្រិតវប្បធម៌ ថ្នាក់ទី១១ នៅលីវ ឪពុកឈ្មោះ [redacted] សុវណ្ណា (រស់) ម្តាយឈ្មោះ [redacted] ចិន្តា (រស់) ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន (គ្មាន) ។

-ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៦១៧ តពជ/២១ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ វណ្ណា កែវខាឃាង ។

៣-ឈ្មោះ [redacted] **វដ្ឋា ហៅ ចយ** ភេទប្រុស អាយុ១៦ឆ្នាំ (កើតឆ្នាំ២០០៥) ជនជាតិខ្មែរ មានទីកន្លែងកំណើត [redacted] ខេត្តកំពត មានទីលំនៅបណ្តោះអាសន្នមុនពេលឃាត់ខ្លួន ភូមិ [redacted] ខេត្តកំពត មុខរបរ មិនពិតប្រាកដ កម្រិតវប្បធម៌ ថ្នាក់ទី៧ នៅលីវ ឪពុកឈ្មោះ [redacted] ជឹម (រស់) ម្តាយឈ្មោះ ភាព (រស់) ជាអនីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន (គ្មាន) ។

-ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៦១៨ តពជ/២១ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១

៤-ឈ្មោះ [redacted] **រ៉ុង ឬ** [redacted] **ពៅ** ភេទប្រុស អាយុ១៦ឆ្នាំ (កើតថ្ងៃទី០៤.០៧.២០០៥) ជនជាតិខ្មែរ មានទីកន្លែងកំណើត [redacted] ខេត្តព្រះសីហនុ មានទីលំនៅបណ្តោះអាសន្នមុនពេលឃាត់ខ្លួន [redacted] ខេត្តព្រះសីហនុ មុខរបរ មិនពិតប្រាកដ កម្រិតវប្បធម៌ ថ្នាក់ទី៥ នៅលីវ ឪពុកឈ្មោះ [redacted] ស៊ា (រស់) ម្តាយឈ្មោះ [redacted] មុំ (រស់) ជាអនីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុន (គ្មាន)

-ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៦១៩ តពជ/២១ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១

**ជាប់ចោទពីបទ៖ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២១ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាម មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

**-ដើមបណ្តឹងរដ្ឋប្បវេណី**

ឈ្មោះ [redacted] ZHONG YING ភេទស្រី ជនជាតិចិន មានទីលំនៅបច្ចុប្បន្ននៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

**-បានឃើញ:** ដីកាសន្និដ្ឋានស្ថាពរលេខ: ៩៦២ អ.យ.គ/២១ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ។

**-បានឃើញ:** ដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ៦២៩២ តព/២១ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ ។

**-បានឃើញ:** ដីកាសម្រេចកំណត់កាលបរិច្ឆេទជំនុំជម្រះលេខ ៦៤៤ តពរ/២២ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តព្រះសីហនុ។

## អង្គហេតុនៃបណ្តឹងចោទប្រកាន់

កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង១៧ និង៣០នាទីយប់ នៅចំណុចក្រោយផ្សារជំរឺ៥ ស្ថិតនៅ ក្រុមទី១៤ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានជនសង្ស័យមួយក្រុម មានឈ្មោះ [redacted] កែវខាឃាង ហៅ ជួយ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះ [redacted] វដ្ឋាហៅ ចយ ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ ,ឈ្មោះ [redacted] ពៅ ឬ ស៊ា រ៉ុង ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ [redacted] តុលា ហៅ ឡា ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ [redacted] លីហួរ ហៅ ហ៊ រ ភេទប្រុស



Scanned with CamScanner

អាយុ១៦ឆ្នាំ ជនជាតិខ្មែរ និងបក្ខពួក បានធ្វើសកម្មភាពដោយជិះម៉ូតូ១គ្រឿង ម៉ាក HONDA DREAM C-125 ពណ៌ក្រហម ផលិតឆ្នាំ២០០៨ គ្មានផ្លាកលេខ ឆក់កាបូបរបស់ជនរងគ្រោះឈ្មោះ [redacted] ZHONG YING ភេទស្រី អាយុ៤៤ឆ្នាំ ជនជាតិចិន (ដោយនៅក្នុងកាបូបមានប្រាក់ដុល្លារចំនួន ១៨០០ ដុល្លារអាមេរិក, ទូរស័ព្ទដៃ ចំនួន២គ្រឿង, លិខិតឆ្លងដែន ចំនួន១ក្បាល និងអត្តសញ្ញាណប័ណ្ណចិន ចំនួន១សន្លឹក) ខណៈដែលជនរងគ្រោះកំពុងដើរតាមផ្លូវក្រោយផ្សារជំរឺ៥ ។ នៅពេលធ្វើសកម្មភាពឆក់នោះ ជនសង្ស័យឈ្មោះ [redacted] គុលា ហៅ ឡា ជាអ្នកបើកម៉ូតូ ហើយជិះពីក្រោយដោយឈ្មោះ សីហា ភេទប្រុស (គេចខ្លួន) ជាអ្នកធ្វើសកម្មភាពឆក់កាបូប បន្ទាប់ពីឆក់បានហើយ ក៏ជិះសំដៅទៅផ្លូវអូរឈើទាល បត់តាមផ្លូវអាឡាំងដីឡុង ឆ្ពោះទៅឃ្លាំងលើចូលក្នុងព្រៃមួយកន្លែងនៅក្បែររោងចក្រញូវស្តារ ដើម្បីឆែកមើលក្នុងកាបូប ហើយក៏បន្តទៅរកបក្ខពួករបស់ឈ្មោះ [redacted] វង្ឍា ហៅ ចយ, ឈ្មោះ [redacted] លីហួរ ហៅ ហ៉រ និងឈ្មោះ ឈិប ភេទប្រុស (គេចខ្លួន) ក្នុងគោលបំណងចែកលុយគ្នា ដោយឈ្មោះ [redacted] គុលា បានប្រាក់ចំនួន២៥០ ដុល្លារអាមេរិក, ឈ្មោះ [redacted] វង្ឍា បានប្រាក់ចំនួន២០០ដុល្លារអាមេរិក ចំណែកនៅសល់ឱ្យឈ្មោះ [redacted] លីហួរ, ឈ្មោះ ឈិប និងឈ្មោះ សីហា ចែកគ្នា រីឯទូរស័ព្ទដៃ ចំនួន២គ្រឿង ឈ្មោះ [redacted] លីហួរ និងឈ្មោះ ឈិប យកទៅលក់នៅម្តុំឃ្លាំងលើ ដើម្បីយកប្រាក់ចែកគ្នាបន្តទៀត។ ក្រោយពេលកើតហេតុ ជនរងគ្រោះខាងលើបានប្តឹងទៅកងរាជអាវុធហត្ថខេត្តព្រះសីហនុ ហើយកម្លាំងសមត្ថកិច្ចជំនាញបានស្រាវជ្រាវ ចុះពិនិត្យ កាមេរ៉ាសុវត្ថិភាពកន្លែងកើតហេតុ និងរហូតឈានដល់ការឃាត់ខ្លួនបានជនសង្ស័យ ចំនួន៥នាក់ នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១១ វេលាម៉ោង១៨ និង០០នាទី នៅចំណុច ផ្ទះជួលមួយ កន្លែងស្ថិតនៅភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ និងបានឆែកឆេររកឃើញម៉ូតូ ចំនួន១គ្រឿង ម៉ាកHONDA DREAM C-125 ពណ៌ខ្មៅ គ្មានផ្លាកលេខ, ទូរស័ព្ទដៃ ចំនួន៤គ្រឿង, កាបូបដៃ ចំនួន១ និងលិខិតឆ្លងដែន ចំនួន១ក្បាល។ ក្រោយការសាកសួរឃើញថា ជនសង្ស័យ ខាងលើ នេះគឺជាបក្ខពួកតែមួយ ដោយមានបក្ខពួករបស់គេផ្សេង ទៀតមានឈ្មោះ ឈិប ភេទប្រុស និងឈ្មោះ សីហា ភេទប្រុស ដែលបានគេចខ្លួន ។ ហើយនៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង៨ និង០០នាទីព្រឹក កម្លាំងការិយាល័យស្រាវជ្រាវបទល្មើសឧក្រិដ្ឋ នៃកងរាជអាវុធហត្ថខេត្តព្រះសីហនុ បានធ្វើតេស្តរកសារធាតុញៀនក្នុងខ្លួន លើជនសង្ស័យដែលឃាត់ខ្លួនខាងលើ ជា លទ្ធផលបង្ហាញ ថាឈ្មោះ [redacted] លីហួរ និងឈ្មោះ [redacted] គុលា មានវិជ្ជមានសារធាតុញៀនក្នុងខ្លួន ចំណែក ជនសង្ស័យ ៣នាក់ទៀត ពុំមានសារធាតុញៀនក្នុងខ្លួនទេ។ ក្រោយការសាកសួរ សមត្ថកិច្ចជំនាញបានក សាងសំណុំរឿង បញ្ជូនជនសង្ស័យ និងវត្ថុតាងមកអយ្យការអមសាលាដំបូង ខេត្តព្រះសីហនុ ដើម្បីបន្តចាត់ការតាមនីតិវិធី ។

**នាពេលសវនាការ**

-ដូចមានក្នុងកំណត់ហេតុស្តីពីការជំនុំជម្រះកាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តព្រះសីហនុ។

**- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ**

**- ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារផ្សេងៗក្នុងសំណុំរឿង**

**- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ**

**- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ**

**- ក្រោយពីបានស្តាប់សំដី និងសំណូមពរចុងក្រោយបង្អស់របស់ជនជាប់ចោទ**

**- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**



Scanned with CamScanner

## សាលាដំបូងខេត្តព្រះសីហនុ
## យល់ឃើញថា

១- ឈ្មោះ [redacted] **លីហួរ ហៅ ហ៊រ** ភេទប្រុស អាយុ១៦ឆ្នាំ (សាវតារជាតិខាងលើ) ត្រូវបានតំណាងអយ្យការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** និងបទ៖ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** , ឈ្មោះ [redacted] **កែវខាឃាង** ហៅ ជួយ ភេទប្រុស អាយុ២០ឆ្នាំ, ឈ្មោះ [redacted] **វដ្ឋា ហៅ ចយ** ភេទប្រុស អាយុ១៦ឆ្នាំ និង ឈ្មោះ [redacted] **រ៉ុង ឬ** [redacted] **ពៅ** ភេទប្រុស អាយុ១៦ឆ្នាំ (សាវតារជាតិខាងលើ) ត្រូវបានតំណាងអយ្យការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** តាមដីកាសន្និដ្ឋានស្ថាពរលេខៈ ៩៦២ អ.យ.ត/២១ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ និង ត្រូវបានចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ បញ្ជូនទៅជំនុំជម្រះតាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ ៦២៩២ ត៣/២១ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ ។

## តស្តុតាងមានៈ

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **លីហួរ** បានឆ្លើយបដិសេធថាៈ ខ្លួនពុំបានចូលរួមក្នុងសកម្មភាពឆក់ទេ ដោយខ្លួនគ្រាន់តែបានជួយយកទូរស័ព្ទពីពេញ្ញាៈ គុលា ទៅលក់ចំនួន ០២ លើកតែប៉ុណ្ណោះ។ ខ្លួនពុំដឹងថាឈ្មោះ គុលា និងបក្ខពួកបានទូរស័ព្ទមកពីណាទេ ហើយក៏ពុំដឹងថាពួកគេធ្វើសកម្មភាពឆក់ទូរស័ព្ទនោះដែរ។ ឈ្មោះ [redacted] **កែវខាឃាង** បានឆ្លើយបដិសេធថាៈ ខ្លួនពុំបានដឹងថាក្រុមរបស់ឈ្មោះ គុលា ជាក្រុមចោរឆក់ទេ ខ្លួនគ្រាន់តែមកដេកនៅបន្ទប់ជួលរបស់ឈ្មោះ គុលា បានពីរយប់តែប៉ុណ្ណោះ ហើយក៏ត្រូវសមត្ថកិច្ចបានចុះមកឃាត់ខ្លួនដល់បន្ទប់តែម្តង។ ឈ្មោះ [redacted] **រ៉ុង** បានឆ្លើយបដិសេធថាៈ ខ្លួនទើបតែស្គាល់ឈ្មោះ គុលា បានប្រហែល ៤ ទៅ ៥ ថ្ងៃប៉ុណ្ណោះ និងមិនដឹងថាឈ្មោះ គុលា ធ្វើសកម្មភាពឆក់ទូរស័ព្ទនោះទេ។ ចម្លើយរបស់ជនជាប់ចោទទាំងនេះ គ្រាន់តែជាការឆ្លើយដោះសារដោយគ្មានភស្តុតាងដោះបន្ទុកគ្រប់គ្រាន់នោះទេ។ តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ តាមចម្លើយរបស់ជនជាប់ចោទនៅដំណាក់កាលនគរបាលយុត្តិធម៌ និងភស្តុតាងនានា នៅក្នុងសំណុំរឿងនេះ ជាពិសេសតាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **វដ្ឋា** ដែលបានឆ្លើយសារភាពនាពេលសវនាការថា ខ្លួនជាម្ចាស់ម៉ូតូម៉ាក HONDA DREAM C-125 ពណ៌ក្រហម គ្មានផ្លាកលេខ ដែលឈ្មោះ គុលា បានយកទៅជិះធ្វើសកម្មភាពឆក់ទូរស័ព្ទ ។ ក្រោយពេលធ្វើសកម្មភាពរួច ឈ្មោះ គុលា បានឱ្យប្រាក់មកខ្លួនចំនួន ២០០ ដុល្លារអាមេរិក ដើម្បីយកទៅបាញ់ថ្នាំម៉ូតូពីពណ៌ក្រហម ទៅពណ៌ខ្មៅវិញ ដើម្បីកុំឱ្យគេចំណាំបាន។ ពួកខ្លួនធ្វើសកម្មភាពជាក្រុម ដោយមានអ្នកចេញឆក់ មានអ្នកយកទូរស័ព្ទទៅលក់ និងមានអ្នកយកម៉ូតូទៅបាញ់ថ្នាំ ជាដើម។ ឃើញថា ក្រុមជនជាប់ចោទទាំងនេះក្រុមចោរឆក់ដែលបានធ្វើសកម្មភាពឆក់ និងបានជួលបន្ទប់ស្នាក់នៅប្រមូលផ្តុំគ្នា និងបានចែកក្រុមគ្នា ធ្វើសម្មភាពជាប្រព័ន្ធ ហើយត្រូវបានសមត្ថកិច្ចឃាត់ខ្លួនបាននៅនឹងបន្ទប់ជួលរួមគ្នាតែម្តង។ អំពើប្រព្រឹត្តរបស់ជនជាប់ចោទទាំងនេះ ពិតជាបានចូលរួមធ្វើសកម្មភាពលួចឆក់ទ្រព្យសម្បត្តិអ្នកដទៃ ពិតមែន អំពើនេះចាត់ទុកថាជាបទល្មើស លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តិអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។

៣-តាមរបាយការណ៍លេខៈ **០៧៣/២០២១ របក** ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ របស់ការិយាល័យព្រហ្មទណ្ឌ នៃកងរាជអាវុធហត្ថខេត្តព្រះសីហនុ បានសន្និដ្ឋានថាៈ ឈ្មោះ [redacted] លីហួរ ហៅ

**ហ៊រ** ភេទប្រុស អាយុ១៦ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** និង **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ។ ឈ្មោះ [redacted] **កែវខាឃាង** ហៅ ជួយ ភេទប្រុស អាយុ២០ឆ្នាំ, ឈ្មោះ [redacted] **វដ្ឋា ហៅ ចយ** ភេទប្រុស អាយុ១៦ឆ្នាំ និង ឈ្មោះ [redacted] **រ៉ុង ឬ** [redacted] **ពៅ** ភេទប្រុស អាយុ១៦ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ពិតប្រាកដមែន។

៤-តំណាងអយ្យការនាពេលសវនាការបានធ្វើសេចក្ដីសន្និដ្ឋានទោសថា៖ តាមការសាកសួរដេញដោលនាពេលសវនាការ ឃើញថាជនជាប់ចោទបានឆ្លើយបដិសេធនូវអំពើប្រព្រឹត្តរបស់ខ្លួន ប៉ុន្តែចម្លើយបដិសេធទាំងនោះ ពុំមានភស្តុតាងដោះបន្ទុកគ្រប់គ្រាន់ទេ។ តំណាងអយ្យការសូមរក្សាបទចោទប្រកាន់ដដែល ដូចមាននៅក្នុង ដីកាសន្និដ្ឋានស្ថាពរលេខៈ ៩៦២ អ.យ.គ/២១ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ប្ដឹងសុំឲ្យតុលាការផ្ដន្ទាទោសលើជនជាប់ចោទទៅតាមច្បាប់ ។

៥-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] **លីហួរ** ឈ្មោះ [redacted] **វដ្ឋា** និងឈ្មោះ [redacted] **រ៉ុង** បានធ្វើសេចក្ដីសន្និដ្ឋានថា៖ ចំពោះកូនក្ដីខ្លួនឈ្មោះ [redacted] រ៉ុង បានឆ្លើយសារភាពថាខ្លួនពុំមានជាប់ពាក់ព័ន្ធនឹងអង្គហេតុនេះទេ។ ស្នើសុំឲ្យតុលាការសម្រេចឲ្យកូនក្ដីខ្លួនឈ្មោះ [redacted] រ៉ុង បានរួចផុតពីបទចោទប្រកាន់។ ចំពោះឈ្មោះ [redacted] **លីហួរ** និងឈ្មោះ [redacted] **វដ្ឋា** ឃើញថាពុំមានជាប់ពាក់ព័ន្ធនឹងអង្គហេតុនៃអំពើលួចមានស្ថានទម្ងន់ទោសនោះទេ ។ ស្នើសុំឲ្យតុលាការសម្រេចកែប្រែពីបទ អំពើលួចមានស្ថានទម្ងន់ទោស ទៅជាបទ ទទួលផលចោរកម្ម លើឈ្មោះ [redacted] **លីហួរ** និងឈ្មោះ [redacted] **វដ្ឋា** វិញ។ តាមសេចក្ដីសន្និដ្ឋានរបស់មេធាវីដែលស្នើសុំនេះ តុលាការយល់ឃើញថាពុំមានភស្តុតាងដោះបន្ទុកគ្រប់គ្រាន់លើកូនក្ដីខ្លួនឡើយ។

៦-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] **កែវខាឃាង** បានធ្វើសេចក្ដីសន្និដ្ឋានថា៖ តាមការពិភាក្សាដេញដោលនាពេលសវនាការ និងតាមចម្លើយរបស់ឈ្មោះ [redacted] តុលា ឃើញថាកូនក្ដីខ្លួន ពុំមានជាប់ពាក់ព័ន្ធនឹងរឿងនេះទេ។ សំណូមពរសុំឲ្យតុលាការសម្រេចលើកលែងចោទប្រកាន់ ឬ បន្ធូរបន្ថយទោសដល់កូនក្ដីខ្លួនផង។ តាមសេចក្ដីសន្និដ្ឋានរបស់មេធាវីដែលស្នើសុំនេះ តុលាការយល់ឃើញថាពុំមានភស្តុតាងដោះបន្ទុកគ្រប់គ្រាន់លើកូនក្ដីខ្លួនឡើយ។

៧-កំណត់ហេតុ និងឯកសារនានា ធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌។

៨-ជនជាប់ចោទ ឈ្មោះ [redacted] **កែវខាឃាង** ហៅ ជួយ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ ជាសមត្ថជន ដែលមានការយល់ដឹងគ្រប់គ្រាន់ (គ្មានវិបល្លាសស្មារតី) ក្នុងការទទួលខុសត្រូវនូវអំពើប្រព្រឹត្តរបស់ខ្លួន។

៩-ជនជាប់ចោទ ឈ្មោះ [redacted] **កែវខាឃាង**, ឈ្មោះ [redacted] **វដ្ឋា** ឈ្មោះ [redacted] **លីហួរ** និងឈ្មោះ [redacted] **រ៉ុង** បាននិយាយសំដី និងសំណូមពរចុងក្រោយបង្អស់សុំឲ្យតុលាការជួយបន្ធូរបន្ថយទោសឲ្យខ្លួនផង ។

**១០-វត្ថុចាប់យករួមមាន៖**

-ម៉ូតូ ០១ គ្រឿងម៉ាកហុងដា C125 គ្មានស្លាកលេខ ។

-ទូរស័ព្ទដៃ ០២ គ្រឿង (ម៉ាក សាំសុង ០១ គ្រឿង និងម៉ាក iPhone ០១ គ្រឿង)

-អាវ ចំនួន ០១ ។

**ត្រូវរឹបអូសតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។**



Scanned with CamScanner

១១-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ZHONG YING ពុំបានប្តឹងទាមទារសំណងរដ្ឋប្បវេណីឡើយ ដូចនេះតុលាការពុំគប្បីសម្រេចអំពីសំណងឡើយ

១២-មានពិរុទ្ធភាពគ្រប់គ្រាន់លើ ឈ្មោះ [redacted] **លីហួរ ហៅ ហ័រ** ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) **ពីបទៈ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៣-មានពិរុទ្ធភាពគ្រប់គ្រាន់លើ ឈ្មោះ [redacted] **កែវខាឃាង** ហៅ ជួយ ភេទប្រុស អាយុ២០ឆ្នាំ, ឈ្មោះ [redacted] **វដ្ឋា ហៅ ចយ** ភេទប្រុស អាយុ១៦ឆ្នាំ និង ឈ្មោះ [redacted] **វ៉ុង ឬ** [redacted] **ពៅ** ភេទប្រុស អាយុ១៦ឆ្នាំ (សាវតារជាតិខាងលើ) ពីបទៈ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

១៤-ជនជាប់ចោទឈ្មោះ [redacted] **លីហួរ ហៅ ហ័រ** ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ ឈ្មោះ [redacted] **វដ្ឋា ហៅ ចយ** ភេទប្រុស អាយុ១៦ឆ្នាំ និង ឈ្មោះ [redacted] **វ៉ុង ឬ** [redacted] **ពៅ** ភេទប្រុស អាយុ១៦ឆ្នាំ ជាអនីតិជន តុលាការគប្បី ផ្តល់ការបន្ថយទោសចំពោះអនីតិជន តាមមាត្រា **១៦០** នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះ
## ចិនិច្ឆ័យសេចក្តី

**ក-ផ្តន្ទាទោសជនជាប់ចោទ ៖**

**១**-ឈ្មោះ [redacted] **លីហួរ ហៅ ហ័រ** ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ០២ **(ពីរ)** ឆ្នាំ ពីបទៈ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៧ និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**២**-ឈ្មោះ [redacted] **វដ្ឋា ហៅ ចយ** ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ **០២ (ពីរ) ឆ្នាំ** ។

**៣**-ឈ្មោះ [redacted] **វ៉ុង** ហៅ ស៊ា ពៅ ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ **០២ (ពីរ) ឆ្នាំ** ។

**ពីបទៈ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៧ និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

៤-ឈ្មោះ [redacted] **កែវខាឃាង** ហៅ ជួយ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ០៣ (បី) ឆ្នាំ ។

**ពីបទៈ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

**ខ-វត្ថុចាប់យករួមមានៈ**

១-ម៉ូតូ ០១ គ្រឿងម៉ាកហុងដា C125 គ្មានស្លាកលេខ ។

២-ទូរស័ព្ទដៃ ០២ គ្រឿង (ម៉ាក សាំសុង ០១ គ្រឿង និងម៉ាក iPhone ០១ គ្រឿង)

៣-អាវ ចំនួន ០១ ។

**ត្រូវរឹបអូសតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។**

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ ឈ្មោះ [redacted] **លីហួរ**, ឈ្មោះ [redacted] **វឌ្ឍា** ឈ្មោះ [redacted] **វ៉ុង** និងឈ្មោះ [redacted] **កែវខាឃាង** និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ZHONG YING និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។ ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] |

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ខេត្តព្រះសីហនុ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner